**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៧២៥ ប្រក កសក

# ប្រកាស

## ស្តីពី

## ការបង្កើតតំបន់ព្រៃឈើសម្រាប់សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ "អូរគ្រៀង"

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ក្រសាស្ត្រ និងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែ

Downloaded from http://www.khmerlaws.com

សម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ៥៣ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីវិធានការនៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ
- បានឃើញប្រកាសលេខ ៥០៩ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

## ស ម្រេ ច

**ប្រការ ១:** បង្កើតតំបន់ព្រៃឈើសម្រាប់សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើតំបន់ព្រៃល្បោះមួយកន្លែង មានឈ្មោះថា **តំបន់សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ អូរគ្រៀង** ដែលមានទីតាំងស្ថិតនៅក្នុងឃុំអូរគ្រៀង និង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ ។

**ប្រការ ២:** ប្រកាសនេះមានគោលបំណងសិក្សាស្រាវជ្រាវៈ

-សារព័ន្ធរុក្ខជាតិនានា និងភាពសំបូរនៃជីវចម្រុះ និងសត្វព្រៃ

-កំណើនលូតលាស់របស់រុក្ខជាតិ

-ដី និងលក្ខណៈអេកូឡូស៊ី

-លក្ខណៈអេកូឡូស៊ីព្រៃឈើតំបន់ខាងកើតទន្លេមេគង្គ

-សំណាករុក្ខជាតិនៃព្រៃល្បោះ

-កត្តាភ្លើងឆេះព្រៃ និង វិធានការទប់ស្កាត់

-កត្តាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងព្រៃល្បោះ ។

**ប្រការ ៣:** តំបន់សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ អូរគ្រៀង មានផ្ទៃក្រឡាសរុបទំហំ ៤,២៧៣ (បួនពាន់ពីររយ ចិតសិបបី) ហិកតា ដូចមានផែនទីមាត្រដ្ឋាន ១:៧៥.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធ ជាខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចនិយាមកា ដូចខាងក្រោម ÷

A- (627000 – 1426205)
B- (627000 – 1433874)
C- (632832 – 1433914)
D- (632790 – 1430000)
E- (632000 – 1430000)
F- (632495 – 1426034)

Downloaded from http://www.khmerlaws.com

**ប្រការ ៤:** តំបន់សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ អូរគ្រៀង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ និងមានភារកិច្ចដូចតទៅ ÷

-គ្រប់គ្រង ការពារ និង អនុវត្តន៍កិច្ចការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើក្នុងតំបន់នេះ

-ធានាឱ្យបាននូវនិរន្តរភាពសម្រាប់ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រពាក់ព័ន្ធនឹងវិស័យព្រៃឈើ

-អាចសហការជាមួយស្ថាប័នសិក្សាស្រាវជ្រាវព្រៃឈើជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍផ្សេងទៀតតាមការចាំបាច់ ។

**ប្រការ ៥:** ដំណើរការ និងការគ្រប់គ្រងតំបន់សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ អូរគ្រៀងនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៦:** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧:** អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលព្រៃឈើ នាយកខុទ្ទកាល័យ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៥

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី ✓
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-សាលាខេត្តក្រចេះ
-ដូចប្រការ ៧
-ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com